ឯកសារបកប្រែ
TRANSLATION/TRADUCTION
ថ្ងៃ ខែ ឆ្នាំ (Date): 12-May-2016, 15:20
CMS/CFO: Sann Rada

**នៅចំពោះមុខអង្គជំនុំជម្រះសាលាដំបូង**
**អង្គជំនុំជម្រះវិសាមញ្ញក្នុងតុលាការកម្ពុជា**
**ព័ត៌មានពិស្តារអំពីការដាក់ឯកសារ**

សំណុំរឿងលេខ: ០០២/១៩-០៩-២០០៧-អ.វ.ត.ក/អ.ជ.ស.ដ

ភាគីដាក់ឯកសារ: សហមេធាវីរបស់លោក នួន ជា

ដាក់ជូន: អង្គជំនុំជម្រះសាលាដំបូង

ភាសាដើម: អង់គ្លេស

កាលបរិច្ឆេទឯកសារ: ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦

**<u>ចំណាត់ថ្នាក់ឯកសារ</u>**

ចំណាត់ថ្នាក់ឯកសារ ស្នើឡើងដោយភាគីដាក់ឯកសារ: សាធារណៈ

ចំណាត់ថ្នាក់ឯកសារដោយអង្គជំនុំជម្រះសាលាដំបូង: **សាធារណៈ/Public**

ចំណាត់ថ្នាក់ប្រភេទឯកសារ:

ពិនិត្យឡើងវិញចំពោះឯកសារចំណាត់ថ្នាក់បណ្ដោះអាសន្ន:

ឈ្មោះមន្ត្រីកត់ត្រា:

ហត្ថលេខា:

---

**សេចក្ដីសន្និដ្ឋានរបស់ នួន ជា អំពីការទទួលយកការសិក្សាអំពីអដ្ឋិធាតុនៅជើងឯក និង ការវាយតម្លៃខាងក្រៅ**

---

**<u>ដាក់ដោយ៖</u>**

**ក្រុមមេធាវីការពារក្ដី នួន ជា**

សុន អរុណ
Victor KOPPE
លីវ សុវណ្ណា
ព្រុំ ផល្លា
សួន វិសាល
Doreen CHEN
Xiaoyang NIE
Marina HAKKOU
Léa KULINOWSKI
DY Socheata

**<u>ផ្ញើជូន៖</u>**

**សហមេធាវីការពារក្ដី ខៀវ សំផន**

គង់ សំអុន
Anta GUISSÉ

**សហព្រះរាជអាជ្ញា៖**

ជា លាង
Nicholas KOUMJIAN

**<u>សហមេធាវី តំណាងដើមបណ្ដឹងរដ្ឋប្បវេណី</u>**

ពេជ អង្គ
Marie GUIRAUD

## I. សេចក្ដីផ្ដើម

1. ដោយអនុលោមតាមសេចក្ដីបង្គាប់របស់អង្គជំនុំជម្រះសាលាដំបូងលេខ **E404** នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦[1] និងតាមវិធាន ៨៧ នៃវិធានផ្ទៃក្នុង សហមេធាវីការពារក្ដីរបស់ នួន ជា ("មេធាវីការពារក្ដី") សូមដាក់ជូននូវសេចក្ដីសង្កេតរបស់ខ្លួនអំពីការទទួលយកជាភស្ដុតាងនៃការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅវាលពិឃាតជើងឯក (ការសិក្សា) និង របាយការណ៍ស្ដីពីការវាយតម្លៃការអភិរក្សអដ្ឋិធាតុជនរងគ្រោះនៅមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក ("របាយការណ៍វាយតម្លៃ")។

## II. សាវតារ

2. នៅថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ មេធាវីការពារក្ដីបានស្នើសុំធ្វើសារណាដោយផ្ទាល់មាត់ទាក់ទិននឹងការទទួលយកជាភស្ដុតាងនូវអត្ថបទមួយដែលបានបោះពុម្ពនៅ *Phnom Penh Post* កាលពីថ្ងៃទី ០៦ ខែ កុម្ភៈ ឆ្នាំ ២០១៦ ដែលមានចំណងជើងថា *Skull by Skull, Team catalogues KR Killings* ("អត្ថបទ") ដើម្បីប្រើប្រាស់ក្នុងពេលសួរដេញដោលសាក្សី គយ តេង[2]។ អត្ថបទនិយាយអំពីការពិនិត្យអដ្ឋិធាតុនៅជើងឯក នៅក្នុងគោលបំណងកំណត់អត្តសញ្ញាណទៅលើ អាយុ ភេទ និង ស្ថានភាពស្លាប់របស់ជនរងគ្រោះ។ ភាគីបានពិភាក្សាដោយផ្ទាល់មាត់នៅថ្ងៃដដែលនៅក្នុងសវនាការ[3]។ សហព្រះរាជអាជ្ញាបានយល់ព្រមថាឯកសារ "មានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅនឹងដំណើរការ"[4] និងថារបាយការណ៍ពេញលេញត្រូវរកឱ្យបាន និងទទួលយកជាភស្ដុតាង[5]។ អង្គជំនុំជម្រះសាលាដំបូងបានទទួលយកអត្ថបទជាភស្ដុតាង និងអនុញ្ញាតឱ្យទទួលបានការសិក្សា[6]។ អង្គជំនុំជម្រះបានពន្យាសេចក្ដីសម្រេចរបស់ខ្លួនលើការទទួលយករបាយការណ៍រហូតដល់ខ្លួនបានទទួលបានការសិក្សា[7]។

---

[1] ឯកសារ **E404** "ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និងការក្រើនរម្លឹកទាក់ទងនឹងសំណើសុំនានាអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត" ថ្ងៃទី០២ ខែ ឧសភា ឆ្នាំ ២០១៦ (**"E404"**)។

[2] សារអេឡិចត្រូនិចពីមេធាវីការពារក្ដីជូនអង្គជំនុំជម្រះ និងភាគី មានចំណងជើងថា "សារណាផ្ទាល់មាត់ថ្ងៃនេះទាក់ទងនឹងការទទួលយក និង ការប្រើប្រាស់ឯកសារមួយ" ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦។

[3] ប្រតិចារិកសវនាការ ថ្ងៃទី ២១ មេសា ឆ្នាំ ២០១៦ នៅ ១១.៣៣.៣៨ ដល់ ១១.៤៣.៤៣។

[4] ប្រតិចារិកសវនាការ ថ្ងៃទី ២១ មេសា ឆ្នាំ ២០១៦ នៅ ១១.៣៩.៣៧។

[5] ប្រតិចារិកសវនាការ ថ្ងៃទី ២១ មេសា ឆ្នាំ ២០១៦ នៅ ១១.៤០.៤៣។

[6] ប្រតិចារិកសវនាការ ថ្ងៃទី ២១ មេសា ឆ្នាំ ២០១៦ នៅ ១១.៣៦.៤៥។

[7] ប្រតិចារិកសវនាការ ថ្ងៃទី ២១ មេសា ឆ្នាំ ២០១៦ នៅ ១១.៣៦.៤៥។

3. នៅថ្ងៃទី ០២ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះសាលាដំបូងបានធ្វើបច្ចុប្បន្នភាពជូនទៅភាគីទាក់ទងនឹងការវិវឌ្ឍន៍នៃការទទួលបានការសិក្សានេះ។ ការសិក្សាមានចំនួន៣២ក្បាលជាភាសាខ្មែរ[8]។ អង្គជំនុំជម្រះបានបញ្ជាក់ថា សៀវភៅចំនួន១២ក្បាលត្រូវបានផ្តល់ជូន អវតក នៅឆ្នាំ២០១៤ និងថា ១១ ក្បាលទៀតមាននៅបណ្ណាល័យរបស់ អវតក ចាប់តាំងពីខែ មករា ឆ្នាំ ២០១៥[9]។ អង្គជំនុំជម្រះបានជម្រាបជូនដល់ភាគីថា ខ្លួនបានទទួលសៀវភៅនៅសល់២១ក្បាល និងការសិក្សាទាំងមូលអាចរកបាននៅបណ្ណាល័យ អវតក សម្រាប់ភាគីពិនិត្យ[10]។

4. អង្គជំនុំជម្រះក៏បានប្រាប់ទៅភាគីថា របាយការណ៍ស្តីពីការវាយតម្លៃការភិរក្សអដ្ឋិធាតុ ត្រូវបានដាក់ចូលក្នុងសំណុំរឿង[11]។ ជាចុងបញ្ចប់អង្គជំនុំជម្រះលើកឡើងថា ខ្លួនត្រូវបានជូនដំណឹងអំពីការសិក្សាស្រដៀងគ្នានេះត្រូវបានធ្វើឡើងនៅខែ មេសា ឆ្នាំ ២០១៦ ទៅលើអដ្ឋិធាតុនៅក្រាំងតាចាន់ ដែលរំពឹងថា នឹងត្រូវបញ្ចប់នៅក្នុងពេលពីរខែខាងមុខនេះ[12]។ អង្គជំនុំជម្រះបានបញ្ជាក់ថា ខ្លួននឹងស្នើសុំការសិក្សានេះ នៅពេលដែលការសិក្សាត្រូវបានបញ្ចប់[13]។

5. ចុងបញ្ចប់ អង្គជំនុំជម្រះបានស្នើដល់ភាគីឱ្យសរសេរសារណា ថាតើការសិក្សាអំពីជើងឯកនេះគួរតែត្រូវបានទទួលជាភស្តុតាង ឬក៏យ៉ាងណា "ដោយពិចារណាដល់ឯកសារមានចំនួនច្រើន និងមានតែជាភាសាខ្មែរ" និងការទទួលយករបាយការណ៍វាយតម្លៃ។ អង្គជំនុំជម្រះបានបង្គាប់ថា សារណាមិនត្រូវលើសពី១០ទំព័រ ហើយត្រូវដាក់ជូននៅថ្ងៃ សុក្រ ទី ០៦ ខែ ឧសភា[14]។ នៅថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦ អង្គជំនុំជម្រះបានពន្យាថ្ងៃកំណត់នេះរហូតដល់ថ្ងៃទី ១២ ខែ ឧសភា ឆ្នាំ ២០១៦ វិញ[15]។

## III. ច្បាប់ជាធរមាន

---

[8] **E404** កថាខណ្ឌ ២។

[9] **E404** កថាខណ្ឌ ២ ដល់ ៣។

[10] **E404** កថាខណ្ឌ ៣។

[11] **E404** កថាខណ្ឌ ៤។

[12] **E404** កថាខណ្ឌ ២។

[13] **E404** កថាខណ្ឌ ៥។

[14] **E404** កថាខណ្ឌ ៥។

[15] សារអេឡិចត្រូនិចពីមន្ត្រីច្បាប់ជូនភាគី "ការជូនដំណឹងអំពីការសិក្សាអដ្ឋិធាតុនៅជើងឯក និងការក្រើនរម្លឹកទាក់ទងនឹងសំណើសុំនានាអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ដែលបានដាក់យឺត" ថ្ងៃទី ០៣ ខែ ឧសភា ឆ្នាំ ២០១៦។

6. រាល់ភស្តុតាងទាំងអស់ត្រូវបានទទួលយក លើកលែងតែមានចែងនៅក្នុងវិធានផ្ទៃក្នុង[16]។ អង្គជំនុំជម្រះអាចបដិសេធសំណើទទួលយកភស្តុតាងក្នុងករណីដែលខ្លួនយល់ឃើញថា ភស្តុតាងមិនមានភាពពាក់ព័ន្ធ ឬក៏ច្រំដែល មិនអាចរកបានក្នុងពេលវេលាសមស្រប មិនអាចបង្ហាញទៅលើអង្គហេតុដែលខ្លួនអាចបង្ហាញ មិនអនុញ្ញាតដោយច្បាប់ ឬក៏នាំឱ្យពន្យារពេលដំណើរការ ឬក៏មិនមានប្រយោជន៍[17]។ ដើម្បីបំពេញលក្ខខណ្ឌនៃវិធាន ៨៧ (៣) ភស្តុតាងដែលត្រូវបានស្នើត្រូវការតែមានភាពពាក់ព័ន្ធ និងអាជឿជាក់បានតាម*ការពិនិត្យបឋម* អាចជឿទុកចិត្តបាន និង មានយថាភាព[18]។ ដោយអនុលោមតាមវិធាន ៨៧ (៤) នៅក្នុងដំណាក់កាលណាក៏ដោយនៅក្នុងអំឡុងពេលសវនាការ ភាគីអាចស្នើសុំឱ្យអង្គជំនុំជម្រះ "ទទួលយកភស្តុតាងថ្មី ដែលមានប្រយោជន៍សម្រាប់នាំមកនូវការស្វែងរកការពិត" ដែលជាកម្មវត្ថុនៃភាពតម្រូវនៃវិធាន៨៧(៣)[19]។ ខណៈដែលវិធាន ៨៧(៤) ចែងថា ភស្តុតាងដែលត្រូវបានស្នើត្រូវតែមិនអាចរកបាននៅក្នុងនៅមុនពេលបើកសវនាការ អង្គជំនុំជម្រះនេះបកស្រាយថា វាជាភស្តុតាងដែលអាចរកបាននៅមុនពេលចាប់ផ្តើមសវនាការ ប៉ុន្តែមិនអាចរកឃើញដោយមានការយកចិត្តទុកដាក់សមស្របនឹងអាចទទួលយក[20]។

7. នៅក្នុងស្ថានភាពជាក់ស្តែងភស្តុតាងដែលមិន"លើកឡើងដោយតឹងរ៉ឹង" បំពេញបានលក្ខខណ្ឌនេះត្រូវបានទទួលយក៖ គឺនៅពេលដែលភស្តុតាងមានភាពពាក់ព័ន្ធយ៉ាងខ្លាំងទៅឯកសារដែលមានស្រាប់នៅចំពោះមុខអង្គជំនុំជម្រះ និងនៅពេលដែលផលប្រយោជន៍យុត្តិធម៌តម្រូវឱ្យមានប្រភពដើម្បីវាយតម្លៃ, នៅពេលដែលភស្តុតាងដែលលើកឡើងជាភស្តុតាងដោះបន្ទុក និងតម្រូវឱ្យមានការវាយតម្លៃ ដើម្បីកុំឱ្យប៉ះពាល់ដល់យុត្តិធម៌, ឬក៏នៅពេលដែលភាគីផ្សេងទៀតមិនបានបដិសេធនឹង

---

[16] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[17] វិធាន ៨៧ (១) នៃវិធានផ្ទៃក្នុង។

[18] ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើដោយអនុលោមតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុងរបស់សហមេធាវីនាំមុខតំណាងដើមបណ្តឹងរដ្ឋប្បវេណីដែលសុំដាក់ភស្តុតាងថ្មីនៅចំពោះមុខអង្គជំនុំជម្រះ (ឯកសារ **E289**) និងចម្លើយតបរបស់ខៀវ សំផន (ឯកសារ **E289/1** )" ថ្ងៃទី ១៤ ខែ មិថុនា ឆ្នាំ ២០១៣ កថាខណ្ឌ ២៦ ("សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)")។

[19] រយៈពេលមួយឆ្នាំនៅក្នុងសវនាការសំណុំរឿង ០០២/០២ អង្គជំនុំជម្រះសាលាដំបូងសម្រេចថា ភាគីអាចដាក់សំណើវិធាន ៨៧(៤) ស្នើសុំឱ្យទទួលយកឯកសារដែលមាននៅក្នុងសំណុំរឿង ប៉ុន្តែមិនត្រូវបានបញ្ចូលនៅក្នុងបញ្ជីឯកសារដែលទទួលយកដោយអង្គជំនុំជម្រះ បើទោះជាឯកសារទាំងអស់នោះត្រូវបានបង្ហាញដោយសហព្រះរាជអាជ្ញាដែលនាំឱ្យមានការស្នើឡើង។ សូមមើលប្រតិចារិកថ្ងៃទី២៦ ខែ មករា ឆ្នាំ២០១៦ ទំព័រ ២៥។

[20] ឯកសារ **E313** "សាលក្រមសំណុំរឿង ០០២/០១" ថ្ងៃទី ០៧ ខែ សីហា ឆ្នាំ ២០១៤ កថាខណ្ឌ ២៥។ ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

ភស្តុតាង[21]។

## IV. ឧទ្ទិករណ៍

### ក. សេចក្តីផ្តើម

8. ដូចដែលបានរៀបរាប់ខាងលើ ការសិក្សាដែលមានចំណងជើងថា *មជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯក: បញ្ជីសារពើភណ្ឌអដ្ឋិធាតុជនរងគ្រោះ* មានចំនួន ៣២ក្បាល។ មេធាវីការពារក្តីពិនិត្យអារម្ភកថា (ដែលមានដូចគ្នាសម្រាប់គ្រប់ក្បាលទាំងអស់) និងបានពិនិត្យអំពីរចនាសម្ព័ន្ធ និងព័ត៌មានដែលមានសម្រាប់ឆ្អឹងលលាដ៏នីមួយៗដែលមានទម្រង់ដូចគ្នាសម្រាប់សៀវភៅនិមួយៗ ដោយសារតែមេធាវីការពារក្តីមិនអាចពិនិត្យសៀវភៅទាំង៣២ក្បាលបានទៅតាមពេលវេលាដែលផ្តល់ជូនដោយអង្គជំនុំជម្រះ។ ការបកប្រែអារម្ភកថាជាភាសាអង់គ្លេស និងឧទាហរណ៍មួយនៃការវិភាគឆ្អឹងលលាដ៏អាចរកបាននៅក្នុង***ឧបសម្ព័ន្ធជាសាធារណៈ III និង IV*** ។

9. អារម្ភកថា លើកឡើងថា ការសិក្សាធ្វើឡើងក្នុងបីដំណាក់កាល។ ដំណាក់កាលទី១ ពីខែ សីហា ឆ្នាំ ២០១៣ ដល់ ខែ សីហា ឆ្នាំ ២០១៤ ការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតធ្ងន់ធ្ងរ។ ដំណាក់កាលទី២ ពីខែ សីហា ឆ្នាំ ២០១៤ ដល់ខែ សីហា ឆ្នាំ ២០១៥ ជាការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតមធ្យម និងដំណាក់កាលទី៣ ពីខែ សីហា ឆ្នាំ ២០១៥ ដល់ ខែ សីហា ឆ្នាំ ២០១៦ ការអភិរក្សអដ្ឋិធាតុដែលមានសភាពខូចខាតដោយការប្រែប្រួលពីលក្ខណៈដើមតិចតួច។ វាហាក់ដូចជាថា ក្រុមសិក្សាអភិរក្សបានពិនិត្យមើលអដ្ឋិធាតុដែលមាន "ស្លាកស្នាមធ្វើទារុណកម្ម ឬ ស្លាកស្នាមនៃការសម្លាប់ដោយប្រើឧបករណ៍ផ្សេងៗ"[22]។

### ខ. ការសង្កេតដំបូងទៅលើពេលវេលារបស់សំណើ

10. មេធាវីការពារក្តីកត់សម្គាល់ថា អនុសាសន៍របស់អង្គជំនុំជម្រះលើភាពយឺតយ៉ាវ ដែលមេធាវីការពារក្តីលើកយកការសិក្សានេះជូនអង្គជំនុំជម្រះ[23]។ អង្គជំនុំជម្រះបានរកឃើញថា ផ្នែកខ្លះនៃការសិក្សាអាចរកបាននៅបណ្ណាល័យ អវតក ចាប់តាំងពីឆ្នាំ២០១៤ ហើយផ្នែកខ្លះទៀតអាចរកបាននៅក្នុងឆ្នាំ២០១៥។ ការសិក្សាទាំងអស់មានតែជាសំណៅសៀវភៅ។ នៅពេលដែលមេធាវីការពារក្តីមានបំណងនឹងអាចពិនិត្យនូវគ្រប់សៀវភៅទាំងអស់ដែលមាននៅបណ្ណាល័យ តែការងារនេះគឺ

---

[21] សូមមើល ឯកសារ **E289/2** "សេចក្តីសម្រេចលើសំណើវិធាន៨៧(៤)" កថាខណ្ឌ ៣។

[22] *សូមមើល* ឧបសម្ព័ន្ធសាធារណៈI។

[23] **E404** កថាខណ្ឌ ៦។

មិនអាចធ្វើទៅបានសម្រាប់ធនធានដែលមាន។ មេធាវីការពារក្តីក៏កត់សម្គាល់ផងដែរថា មិនមានប្រព័ន្ធអេឡិចត្រូនិចសម្រាប់ឲ្យភាគីស្រាវជ្រាវទៅលើឯកសារដែលមាននៅបណ្ណាល័យ។ ជាចុងបញ្ចប់អង្គជំនុំជម្រះខ្លួនឯងផ្ទាល់ បានកត់សម្គាល់ថា សៀវភៅ២១ក្បាលមិនមានទេ ហើយទើបតែទទួលបានក្នុងពេលថ្មីៗនេះ[24]។

11. មួយវិញទៀតមេធាវីការពារក្តីចង់គូសបញ្ជាក់ថា ទាំង កសចស កសព ឬអង្គជំនុំជម្រះសាលាដំបូង មិនបានលើកឡើងពីការសិក្សាខាងលើនេះទេ ហើយវាហាក់ដូចជាថា កសព ខ្លួនឯង ក៏មិនបានដឹងពីការសិក្សានេះដែរ ថ្វីបើខ្លួនមានបន្ទុកនៃការបង្ហាញភស្តុតាងក៏ដោយ[25]។ មេធាវីការពារក្តីកត់សម្គាល់បន្ថែមទៀតថា ខណៈដែលអង្គជំនុំជម្រះសាលាដំបូងហាក់ដូចជាបានដឹងពីអត្ថិភាពរបស់វា តាមរយៈ Press Clippings អ.វ.ត.ក[26] និងបើទោះបីអង្គជំនុំជម្រះមានកាតព្វកិច្ចដើម្បីស្វែងរកការពិត និងទទួលយកជាភស្តុតាងនូវការសិក្សានេះដែលខ្លួនចាត់ទុកថាមានប្រយោជន៍ដល់ការបញ្ជាក់ការពិត ស្របតាមវិធាន ៨៧(៤) នៃវិធានផ្ទៃក្នុង ក៏អង្គជំនុំជម្រះសាលាដំបូង ខកខានមិនបានពិភាក្សាបពីវត្តមាននៃការសិក្សាជាមួយភាគីដែរ ។

## គ. ការសង្កេតទាក់ទងនឹងការសិក្សាអំពីជើងឯក

### *(i) ការសិក្សានេះ គឺមានភាពពាក់ព័ន្ធមានកំណត់*

12. បើក្រឡេកមួយភ្លែត កម្មវត្ថុនៃការសិក្សានេះ ហាក់ដូចជាពាក់ព័ន្ធនឹងសំណុំរឿងបច្ចុប្បន្ន ដោយសារវាទាក់ទងនឹងការចោទប្រកាន់អំពីការសម្លាប់នៅជើងឯក ដែលបានយោងនៅក្នុងកថាខណ្ឌ ៤៦៣ ដល់៤៦៧ នៅក្នុងដីកាដំណោះស្រាយ[27]។ ការសិក្សានេះក៏ទាក់ទងទៅនឹងភស្តុតាងដ៏ច្រើននៅក្នុងសំណុំរឿងផងដែរ រួមទាំង *ក្នុងចំណោមបញ្ហាផ្សេងទៀត* ភស្តុតាងរបស់ តយ តេង និង ហ៊ឹម ហ៊ុយ E3/8767: ការស្រាវជ្រាវកោសលវិច័យលើបូជនីយដ្ឋានបីកន្លែងដែលមានឆ្អឹងលលាដ៏ក្បាលនៅក្នុងព្រះរាជាណាចក្រកម្ពុជាដោយ M. S. Pollanen, ទីប្រឹក្សាផ្នែកកោសលវិច័យ (Forensic Pathology Consultant) ឬក៏អត្ថបទនៅ *Phnom Penh Post* មានចំណងជើងថា *Skull by Skull, Team Catalogues KR Killings*, ដែលត្រូវបានទទួលយកជាភស្តុតាងនៅថ្ងៃទី ២១ ខែ

---

[24] **E404** កថាខណ្ឌ ៣។

[25] ប្រតិចារិតសវនាការថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៦ (ពង្រាង តៃ តេង) នៅ 11.39.37 ។

[26] ប្រតិចារិតសវនាការថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៦ (ពង្រាង តៃ តេង) នៅ 11.35.46 ។

[27] **D427** ដីកាដំណោះស្រាយ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១០ ។

មេសា ឆ្នាំ ២០១៦[28]។

13. តែមេធាវីការពារក្ដីកត់សម្គាល់ថា គោលបំណងចម្បងនៃការសិក្សានេះហាក់ដូចជាការអភិរក្សអដ្ឋិធាតុ និងឆ្អឹងលលាដ៍ក្បាលប៉ុណ្ណោះ[29]។ វាមិនមែនជាការសិក្សាបែបកោសលវិច័យសម្រាប់ដំណើរការនីតិវិធីផ្នែកច្បាប់ទេ តែវាជា"ការសិក្សាអដ្ឋិវិទ្យាជាមួយនឹងការផ្ដោតយកចិត្តទុកដាក់លើដំណើរការទង្គិចយ៉ាងខ្លាំងលើឆ្អឹងលលាដ៍ក្បាល"[30]។ ម្យ៉ាងទៀតវាហាក់ដូចជាថា ការសិក្សានេះផ្អែកលើការស្រាវជ្រាវដែលធ្វើឡើងនៅក្នុងបរិបទជំហានទី១ និងជំហានទី២ នៃការសិក្សានេះតែប៉ុណ្ណោះ ជាពិសេសការសិក្សានៃឆ្អឹងលលាដ៍ក្បាលដែលខូចខាតយ៉ាងខ្លាំងនិងមធ្យម ដោយសារជំហានទី៣ នៃការសិក្សានេះ ដែលទាក់ទងនឹងឆ្អឹងលលាដ៍ក្បាលដែលខូចខាតតិចតួច ហាក់ដូចជាកំពុងដំណើរការនៅពេលថ្មីៗនេះ ហើយគ្រោងនឹងបញ្ចប់នៅដំណាច់ខែ សីហា ឆ្នាំ ២០១៦នេះ[31]។ ដូច្នេះការសិក្សានេះមិនបានផ្ដល់រូបភាពពេញលេញនៃអដ្ឋិធាតុនៅជើងឯកឡើយ ។

14. ជាលទ្ធផលមេធាវីការពារក្ដីយល់ឃើញថា ភាពពាក់ព័ន្ធនៃការសិក្សានេះគឺកម្រិតបំផុត។ អង្គហេតុដែលថា ការសិក្សានេះមិនមានបំណងឲ្យទៅជាការសិក្សាបែបកោសលវិច័យ គឺប្រឆាំងនឹងការទទួលយកវាជាភស្ដុតាងដែរ ដោយសារវាបង្ហាញពីកង្វះខាតនៃភាពអាចទុកចិត្តបានសម្រាប់គោលបំណងនៃដំណើរការនីតិវិធីផ្នែកច្បាប់។

### *(ii) ការសិក្សានេះ គឺមិនអាចទុកចិត្តបានជាបឋម*

15. ខណៈដែលការសិក្សានេះមានព័ត៌មានអំពីសញ្ញានៃដំណើរទង្គិចយ៉ាងខ្លាំង មេធាវីការពារក្ដីចង់រំលេចពីកង្វះព័ត៌មានទាក់ទងនឹងវិធីសាស្ត្រ ដែលបានប្រើប្រាស់ដើម្បីកំណត់ "ដំណើរទង្គិចយ៉ាងខ្លាំង" ដែលត្រូវបានចោទប្រកាន់ ។ ម្យ៉ាងទៀតការសិក្សានេះមានការរកឃើញមួយចំនួន តែមិនបានផ្ដល់ការធ្វើយុត្តិកម្មបែបវិទ្យាសាស្ត្រ ដូចជាការសន្និដ្ឋានថា ឧបករណ៍ជាក់លាក់ត្រូវបានប្រើប្រាស់ប្រឆាំងនឹងឆ្អឹងលលាដ៍ក្បាល[32] ឬថា ជនរងគ្រោះជាក់លាក់មួយចំនួន "ត្រូវបានគេធ្វើទារុណកម្មយ៉ាងព្រៃផ្សៃនៅមុនពេលសម្លាប់"[33]។

---

[28] ប្រតិចារិតសវនាការថ្ងៃទី២១ ខែមេសា ឆ្នាំ ២០១៦ (ពង្រាង តៃ តេង) នៅម៉ោង ១៣ និង៣៥នាទី ។

[29] សូមមើលសម្ព័ន្ធសធារណៈ I ។

[30] **E404** នៅកថាខណ្ឌ២។

[31] សូមមើលសម្ព័ន្ធសធារណៈ I ។

[32] សូមមើលសម្ព័ន្ធសធារណៈ II ។

[33] សូមមើលសម្ព័ន្ធសធារណៈ III ។

16. ជាចុងក្រោយក៏មិនមានការចង្អុលបង្ហាញថា តើឆ្អឹងលលាដ៏ក្បាល និងអដ្ឋិធាតុយកពីទីកន្លែងណាដែរ ហើយក៏មិនមានព័ត៌មានទាក់ទងនឹងទីកន្លែង និងពេលវេលានៃការគាស់ចេញពីរណ្ដៅនៃឆ្អឹងលលាដ៏ក្បាល និងអដ្ឋិធាតុ និងខ្សែរសង្វាក់នៃការគ្រប់គ្រងដែរ។ ពុំមានភស្តុតាងដែលថាឆ្អឹងលលាដ៏ក្បាល និងអដ្ឋិធាតុទាំងនោះពាក់ព័ន្ធជាមួយមន្ទីរស២១ ឬរបបកម្ពុជាប្រជាធិបតេយ្យដែរ ពិព្រោះអ្នកនិពន្ធនៃការសិក្សានេះ ហាក់ដូចជាមិនបានធ្វើការសិក្សាបែបវិទ្យាសាស្ត្រណាមួយដើម្បីចុះកាលបរិច្ឆេទឆ្អឹងលលាដ៏ក្បាល និងអដ្ឋិធាតុទេ។ សំខាន់ជាងនេះទៅទៀតនោះ ដោយសារតែជើងឯកធ្លាប់ជាកន្លែងបញ្ចុះសពនៅមុនឆ្នាំ ១៩៧៥ ដូចនេះហើយនៅទីតាំងនេះមានអដ្ឋិធាតុរួចជាស្រេចហើយ[34]។ ព័ត៌មានដូចនេះ វារិតតែសំខាន់ទៅទៀតនោះ បើយោងទៅភស្តុតាងដែលផ្តល់ដោយ គយ តេង ដែលជាអ្នកទទួលខុសត្រូវនៅជើងឯក វាហាក់ដូចជាមានតែមនុស្សប្រហែល៣០០ ប៉ុណ្ណោះដែលត្រូវបានសម្លាប់នៅជើងឯក[35]។

17. ដោយពិចារណាមូលហេតុខាងលើ មេធាវីការពារក្តីយល់ឃើញថា ការសិក្សានេះខកខានមិនបានបំពេញលក្ខខណ្ឌជាអប្បបរមានៃភាពអាចទុកចិត្តបានជាបឋមឡើយ។

***(iii) យថាភាព***

18. មេធាវីការពារក្តីមិនជំទាស់យថាភាព*ជាបឋម*នៃការសិក្សានេះឡើយ ដោយសារ វាត្រូវបានរៀបចំឡើងនៅក្រោមការត្រួតពិនិត្យរបស់លោក វឿន វុទ្ធី ដែលបច្ចុប្បន្ននេះជានាយក នៃនាយកដ្ឋានបុរាណវិទ្យា និង បុរេប្រវត្តិសាស្ត្រនៃក្រសួងវប្បធម៌ និង វិចិត្រសិល្បៈ និងជានាយកមន្ទីរពិសោធន៍អដ្ឋិវិទ្យា និងអភិរក្សនៃមជ្ឈមណ្ឌលប្រល័យពូជសាសន៍ជើងឯកភ្នំពេញ[36]។

***(iv) ការសង្កេតទាក់ទងនឹងកម្រាស់ និង ភាសា***

19. មេធាវីការពារក្តីយល់ឃើញថា កម្រាស់របស់ឯកសារ គឺមិនពាក់ព័ន្ធទៅនឹងការទទួលយកជាភស្តុ

---

[34] សូមមើល **E3/7617** "កំណត់ហេតុស្តាប់ចម្លើយ គយ តេង" ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ២០០៨ ERN EN 00401879។ "សម្តេងពីមន្ទីរស ២១" ERN EN 00192832។ កំណត់ហេតុស្តាប់ចម្លើយ ឈុន ផល ERN EN 00163815។

[35] គយ តេង បានផ្តល់សក្ខីកម្មថា ជាមធ្យម ខ្លួនបានជីករណ្តៅពី២ ទៅ៣ ដែលមានទំហំ ៣x២x២ ម៉ែត្រ ហើយដែលអាចដាក់សាកសពពី ១០ ទៅ២០។ សូមមើលប្រតិចារិកសវនាការ ថ្ងៃទី ២១ ខែ មេសា ឆ្នាំ ២០១៦ នៅត្រង់ ១៥.១៤.៥២។ និងមើលផងដែរ E3/7617 កំណត់ហេតុស្តាប់ចម្លើយ គយ តេង ថ្ងៃទី១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ នៅ ERN EN 00401877-78។ នៅដើមខែ កុម្ភៈ ឆ្នាំ ២០០៨ គាត់ប្រាប់ កសចស ថា គាត់ប៉ាន់ស្មានមានរណ្តៅទាំងអស់ពី ២០ ទៅ៣០ រណ្តៅ។ E3/7617 កំណត់ហេតុស្តាប់ចម្លើយ គយ តេង ថ្ងៃទី ១៩ ខែ កុម្ភៈ ឆ្នាំ ២០០៨ នៅ ERN EN 00401879 ។

[36] សូមមើលជីវៈប្រវត្តិរបស់លោក វឿន វុទ្ធី នៅ https://crowd.instrumentl.com/campaigns/preserving-evidence-khmer-rouge-genocide/ .

តាងឡើយ។ ខណៈដែលមានការបារម្ភពីអនុវត្តទាក់ទងនឹងបញ្ហានៃការបកប្រែ មេធាវីការពារក្ដីយល់ឃើញថា អ្នកដែលអាចជំនះដោយងាយស្រួលតាមរយៈការជ្រើសរើសទំព័រជាក់លាក់ដោយភាគី ដើម្បីបង្កើតការបកប្រែចំណែកនៃភស្តុតាង ដូចដែលបានអនុវត្តទៅលើសៀវភៅមួយចំនួនដែលត្រូវបានទទួលយកជាភស្តុតាង[37] និងត្រូវបានសំអាងដោយអង្គជំនុំជម្រះនេះនៅក្នុងសាលក្រមនៅក្នុងសំណុំរឿង០០២/០១[38] ។

20. មេធាវីការពារក្ដីយល់ឃើញទៀតថា មិនមានលក្ខខណ្ឌតម្រូវដែលថា ឯកសារត្រូវតែបានបកប្រែទៅជាភាសាផ្លូវការទាំងអស់របស់តុលាការ នៅមុនវាត្រូវបានទទួលយកជាភស្តុតាងឡើយ។ វិធាន ៨៧ នៃវិធានផ្ទៃក្នុង ដែលចែងពីការទទួលយកភស្តុតាង មិនបាននិយាយពីលក្ខខណ្ឌតម្រូវនេះដែរ។ មេធាវីការពារក្ដីរំលឹកថា នៅក្នុងសំណុំរឿង០០២/០១ អង្គជំនុំជម្រះសាលាដំបូងអនុញ្ញាតឲ្យភាគីប្រើឯកសារនៅសវនាការ បើទោះបីការបកប្រែពុំអាចរកបាននៅក្នុងភាសាផ្លូវការទាំងអស់របស់តុលាការ។ ការរង់ចាំការបកប្រែត្រូវការពេលវេលាសម្រាប់ការដាក់សេចក្ដីសន្និដ្ឋានបិទ[39]។ មេធាវីការពារក្ដីយល់ឃើញថា វិធីសាស្ត្រដូចគ្នាត្រូវតែបានបង្កើតឡើងនៅក្នុងសំណុំរឿងនេះ ហើយថាភាគីត្រូវបានអនុញ្ញាតឲ្យដាក់ឯកសារដើម្បីទទួលយកជាភស្តុតាង ដែលអាចរកបានតែនៅក្នុងភាសាផ្លូវការមួយរបស់តុលាការ ។

21. ការរកឃើញផ្ទុយពីនេះនឹងដាក់បន្ទុកយ៉ាងអយុត្តិធម៌មកលើភាគី ហើយជាពិសេសមកលើមេធាវីការពារក្ដី។ តាមពិតដោយសារធនធានរបស់អង្គភាពបកប្រែ និងផ្ទាល់មាត់របស់តុលាការ និង អ្នកបកប្រែរបស់ក្រុមមេធាវីការពារក្ដី មានបន្ទុកច្រើនហួស មេធាវីការពារក្ដីមិនអាចផ្ដល់ការបកប្រែជាបីភាសាឲ្យទាន់ពេលវេលាឡើយ។ អាស្រ័យហេតុនេះត្រូវបានរាំងពីការបង្ហាញភស្តុតាងឲ្យ

---

[37] សូមមើលឧទាហរណ៍ E3/1664, E3/1683, E3/3304, E3/1813

[38] សូមមើលឧទាហរណ៍ William Shawcross, *Sideshow: Kissinger, Nixon and the Destruction of Cambodia*, ដែលគ្មានការបកប្រែទៅជាភាសាបារាំង ហើយមានតែផ្នែកខ្លះត្រូវបានបកប្រែទៅជាភាសាខ្មែរ ។ **E3/9**, Philip Short, *Pol Pot: The History of a Nightmare*, មានមួយផ្នែកត្រូវបានបកប្រែទៅជាភាសាខ្មែរ ។ **E3/1815**, Ben Kiernan, How Pol Pot Came to Power, មានបកប្រែទៅជាភាសាបារាំងនូវផ្នែកខ្លះប៉ុណ្ណោះ ។

[39] **E223/2/6/1**ប៉ុណ្ណោះ "សេចក្ដីសម្រេចលើសំណើរបស់សហព្រះរាជអាជ្ញាស្នើសុំបង្កើតនីតិវិធីពាក់ព័ន្ធនឹងការទទួលយកឯកសារ ដែលមិនបានបកប្រែគ្រប់ភាសាទាំងអស់របស់ អវតក (ឯកសារ E223/2/6) និងចម្លើយតបរបស់សហមេធាវីនាំមុខទៅនឹងសេចក្ដីណែនាំរបស់អង្គជំនុំជម្រះសាលាដំបូងស្ដីពីការដាក់ចម្លើយរបស់ដើមបណ្ដឹងរដ្ឋប្បវេណី និង ឯកសារផ្សេងៗ (ឯកសារ E223/2/7 និង E223/7/1)"។

មានប្រសិទ្ធិភាព ដូច្នេះរំលោភសិទ្ធិរបស់ នួន ជា ដើម្បីបង្ហាញភស្តុតាង[40] ។

## ឃ. ការសង្កេតអំពីរបាយការណ៍វាយតម្លៃ

22. មេធាវីការពារក្តីកត់សម្គាល់ថា របាយការណ៍វាយតម្លៃនេះមិនពាក់ព័ន្ធជាមួយការសិក្សានេះទេ ហើយដូច្នេះវាមិនត្រូវទទួលយកជាភស្តុតាងទេ ប្រសិនបើការសិក្សានេះមិនត្រូវបានទទួលយកជាភស្តុតាង។ ជាជម្រើសម្យ៉ាងទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកការសិក្សានេះជាភស្តុតាង របាយការណ៍វាយតម្លៃក៏ត្រូវទទួលយកជាភស្តុតាងដែរ ដោយសាររបាយការណ៍វាយតម្លៃនេះត្រូវបានរៀបចំឡើងដោយបុគ្គលម្នាក់ ដែលមានបទពិសោធន៍វាយតម្លៃគម្រោងនានា ហើយវិធីសាស្ត្រដែលបានប្រើប្រាស់ដើម្បីវាយតម្លៃការសិក្សានេះ បានបង្ហាញយ៉ាងច្បាស់។ ដូច្នេះ មេធាវីការពារក្តីយល់ឃើញថា របាយការណ៍នេះ គឺមានសញ្ញាណនៃភាពអាចទុកចិត្តបាន*ជាបឋម* (*prima facie* indicia) និងភាពជឿជាក់ និងយថាភាព។

## V. សំណើ

23. អាស្រ័យដោយមូលហេតុដែលបានបញ្ជាក់ពីខាងលើមេធាវីការពារក្តីយល់ឃើញថា ការសិក្សានេះមិនត្រូវទទួលយកជាភស្តុតាងឡើយ ដោយសារវាខកខានមិនបំពេញលក្ខខណ្ឌតម្រូវជាអប្បបរិមានៃភាពពាក់ព័ន្ធ និង ភាពអាចទុកចិត្ត ដូចដែលបានតម្រូវដោយវិធាន ៨៧(៣)នៃវិធានផ្ទៃក្នុង។ ជាលទ្ធផលរបាយការណ៍វាយតម្លៃក៏មិនត្រូវទទួលយកជាភស្តុតាងដែរ។

24. ជាជម្រើសម្យ៉ាងទៀត ប្រសិនបើអង្គជំនុំជម្រះសាលាដំបូងទទួលយកការសិក្សានេះជាភស្តុតាង របាយការណ៍វាយតម្លៃក៏ត្រូវទទួលយកជាភស្តុតាងដែរ។ បន្ថែមពីលើនេះលោក វឿន វុទ្ធី អ្នកនិពន្ធការសិក្សានេះត្រូវតែបានកោះហៅឱ្យផ្តល់សក្ខីកម្មដើម្បីផ្តល់ភស្តុតាងនៃវិធីសាស្ត្រ និង ដំណើរការដែលបានប្រើប្រាស់នៅក្នុងការរៀបចំការសិក្សានេះ។

**សហមេធាវីការពារក្តី នួន ជា**

សុន អរុណ Victor KOPPE

[40] មាត្រា ៣៥(ង)ថ្មី នៃច្បាប់បង្កើត អវតក ។